**សាធារណរដ្ឋប្រជាមានិតកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋ**

លេខ: ០៨ ក្រ ច

# ក្រឹត្យ- ច្បាប់

# ស្តីពី

# បទល្មើសមានលក្ខណ:យោធា និង ទណ្ឌកម្ម

# ក្រុមប្រឹក្សា រដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិត្យកម្ពុជា ។
- ដើម្បីការពារសន្តិសុខ ការពារប្រទេស ការពារ កម្លាំងប្រយុទ្ធ របស់កងកម្លាំងប្រដាប់អាវុធ ប្រជាជនបដិវត្ត កម្ពុជា ពង្រឹង វិន័យ របស់ កងទ័ពនិង ការពារនីត្យានុកូលភាព ។
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងការពារប្រទេស និង រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ។
- ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រមផង ។

**សំរេច**

**មាត្រា ១** - គោលការណ៍បង្ក្រាប បទល្មើស ។

គ្រប់អំពើល្មើស ដែលធ្វើអោយប៉ះពាល់ ដល់កម្លាំងប្រយុទ្ធ របស់ កម្លាំងប្រដាប់អាវុធ ប្រជាជនបដិវត្ត កម្ពុជា និង ដល់ បទបញ្ជា នៃ បរិចារកិច្ច យោធា ត្រូវរកអោយឃើញទាន់ពេលវេលា និង ផ្តន្ទាទោសតាមសមធម៌ ។

អំពើញុះញង់ ឬ ជំរុញជនច្រើនរូប អោយប្រព្រឹត្តិ បទល្មើស ព្រហ្មទណ្ឌណាមួយ ត្រូវផ្តន្ទាទោសយ៉ាងទម្ងន់ ។ អំពើដែលបណ្តាលអោយមានការខូចខាត ធ្ងន់ធ្ងរ ឬ ធ្វើអោយប៉ះពាល់ជាខ្លាំង ដល់ការបំពេញភារកិច្ច របស់អង្គភាពទ័ព ក៏ត្រូវផ្តន្ទាទោស ជាទម្ងន់ដែរ ។ ជនណា ដែលបានបង្ហាញដោយស្មោះត្រង់ នូវសេចក្តីស្តាយក្រោយ អំពីកំហុសរបស់ខ្លួន ហើយបានបង្កើតស្នាដៃ ណាមួយ ដើម្បីលុបលាង កំហុសនោះ អាចត្រូវបាន សន្តោសទោស ឬ លើកលែងទោស ។

**មាត្រា ២** - ការប្រឆាំងនឹងបញ្ជារបស់ថ្នាក់លើ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
Downloaded from http://www.khmerlaws.com
Downloaded from http://www.khmerlaws.org

យោធាណាដែលប្រឆាំងជាសាធារណៈ នឹងបញ្ជាថ្នាក់លើ ទាក់ទងនឹង ករណីកិច្ចយោធាសំខាន់ៗឬ មិនព្រមអនុវត្តបញ្ជានេះ ឬ ប្រព្រឹត្តិ ដោយចេតនា និង ដោយផ្ទុយនឹងបញ្ជានេះ ត្រូវផ្តន្ទាទោសដាក់គុក ពី ៦ ខែ ទៅ ៣ ឆ្នាំ ។

បើការប្រឆាំងនឹង បញ្ជា ធ្វើឡើងក្នុងពេលប្រយុទ្ធ ឬ ក៏អូសទាញជនច្រើន រូបនៅពេលជាមួយគ្នា អោយប្រឆាំងនឹងបញ្ជានោះ បណ្តាលអោយមានផលអាក្រក់ ជាទម្ងន់ ជនប្រព្រឹត្តិ បទល្មើសអាចត្រូវផ្តន្ទាទោស ដាក់គុករហូតដល់ ១០ ឆ្នាំ ។ បើផលអាក្រក់ មានលក្ខណៈធ្ងន់ធ្ងរ ជាពិសេស ជនប្រព្រឹត្តិបទល្មើសអាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ២០ឆ្នាំ ឬដាក់គុកអស់មួយជីវិត ឬប្រហាជីវិត។

**មាត្រា ៣** – ការចុះចូលជាមួយខ្មាំង

យោធាណាចុះចូលជាមួយខ្មាំងត្រូវផ្តន្ទាទោសដាក់គុក ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ។ បើមានការញុះញង់ ឬ ជំរុញជនច្រើនរូប អោយចូលរួម ប្រព្រឹត្តិ បទល្មើស នៅពេលជាមួយគ្នា ឬ បើមានយកទាំងអាវុធ និង ឯកសារសំខាន់ៗ ទៅជាមួយផង ជនប្រព្រឹត្តិបទល្មើស អាចត្រូវផ្តន្ទាទោស ដាក់គុករហូតដល់ ១០ ឆ្នាំ ។

ប្រសិនបើអំពើប្រព្រឹត្តិ នាំមកនូវផលអាក្រក់ ធ្ងន់ធ្ងរជាពិសេស ជនប្រព្រឹត្តិ បទល្មើស អាចត្រូវផ្តន្ទាទោស ដាក់គុករហូតដល់ ២០ ឆ្នាំ ឬ ដាក់គុកអស់មួយជីវិត ឬ ប្រហាជីវិត ។

**មាត្រា៤** – ការលួច ការលក់ ការទិញ ការជួយលក់គ្រឿងអាវុធ បរិក្ខា សំលៀកបំពាក់ ឬ ប្រដាប់ប្រដាមានតម្លៃច្រើនផ្សេងៗ ទៀត របស់ កងទ័ព ។

ជនណាលួចលក់ ទិញ ជួយ លាក់គ្រឿងអាវុធ បរិក្ខា សំលៀកបំពាក់ ប្រដាប់ប្រដាមានតំលៃច្រើនផ្សេងៗទៀត របស់កងទ័ព ត្រូវផ្តន្ទាទោសដាក់គុក ពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ ។ ក្នុង ករណីធ្ងន់ធ្ងរ ជនប្រព្រឹត្ត បទល្មើស អាច ត្រូវផ្តន្ទាទោស រហូតដល់ ១០ ឆ្នាំ។

ម្យ៉ាងទៀត ជនប្រព្រឹត្តិ បទល្មើស អាចត្រូវ ផ្តន្ទាទោស ពិន័យជាប្រាក់រៀល ដែលនឹងកំណត់ទៅតាមលក្ខណៈ និង កំរិតនៃការខូចខាត បណ្តាលមកពីអំពើល្មើស ។

**មាត្រា ៥** – ការគំរាមកំហែង ភ្នាក់ងាររដ្ឋការ។

យោធាណាដែលអាងលើមុខងារ របស់ខ្លួន អំណាចរបស់ ខ្លួន ឬ អាងលើកម្លាំងគ្នាច្រើន ប្រដាប់អាវុធ ដើម្បី គំរាមកំហែង អ្នករដ្ឋការណាមួយ ដែល កំពុងបំពេញភារកិច្ច បង្ខំអោយជននោះ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
Downloaded from http://www.khmerlaws.com
Downloaded from http://www.khmerlaws.org

បោះបង់ករណីកិច្ច របស់ ខ្លួន និង ឬ អោយប្រព្រឹត្តិផ្ទុយ នឹងករណីកិច្ចដែលជននោះត្រូវធ្វើ ត្រូវផ្តន្ទាទោស ដាក់គុក ពី ៦ ខែ ទៅ ៣ ឆ្នាំ ។ បើអំពើប្រព្រឹត្តិ នាំមកនូវផលអាក្រក់ធ្ងន់ធ្ងរ ជនប្រព្រឹត្តិបទល្មើស អាចត្រូវផ្តន្ទាទោស ដាក់គុករហូតដល់ ១០ ឆ្នាំ ។

**មាត្រា ៦** – ការឃោសនា បំផ្លិចបំផ្លាញ ដើម្បី បំបែកបំបាក់ កងទ័ព ។

ជនណា ធ្វើការ ឃោសនា បំផ្លិចបំផ្លាញ ប្រឆាំងនឹងគោលនយបាយ ប្រឆាំងនឹងនយោបាយជាក់ស្តែង របស់បដិវត្តន៍ ដើម្បី ធ្វើអោយប៉ះពាល់ ដល់ទឹកចិត្ត កងទ័ពដល់សាមគ្គីភាព នៃ កងទ័ព ឬ ដើម្បី ធ្វើអោយមានការបែកបាក់ រវាងកងទ័ព និង ប្រជាជន , រវាងកងទ័ពនិង ផ្នែកនានា ត្រូវផ្តន្ទាទោសដាក់គុក ពី ៦ ខែ ទៅ ៣ឆ្នាំ។

**មាត្រា ៧** – ការវាយដំនិង ការធ្វើអោយមានការរបួស ។

ក្នុងការទាក់ទង រវាងអ្នកបញ្ជា និង អ្នកទទួលបញ្ជា យោធាណាដែលប្រព្រឹត្តិ អំពើ ហឹង្សា ធ្វើអោយប៉ះពាល់ ដល់រូបកាយ របស់កម្មាភិបាល ថ្នាក់បញ្ជា ឬ កម្មាភិបាល ថ្នាក់បញ្ជាណាដែលវាយដំ ឬ ធ្វើបាបអ្នកដែលនៅក្រោមបង្គាប់របស់ខ្លួន ត្រូវ ផ្តន្ទាទោសដាក់គុក ពី ៦ ខែ ទៅ ៣ ឆ្នាំ ។ បើអំពើប្រព្រឹត្តិ បណ្តាលអោយមានរបួសធ្ងន់ ឬ បណ្តាលអោយស្លាប់ ជនប្រព្រឹត្តិបទល្មើស ត្រូវ ផ្តន្ទាទោស ពី បទវាយដំ និង ធ្វើអោយគេមានរបួស ដោយចេតនាឬ ពីបទធ្វើមនុស្សឃាដ ។

ក្នុងករណីខាងក្រោមនេះ ការផ្តន្ទាទោស ត្រូវអនុវត្តតាមប្រការ ៧ នៃក្រឹត្យ ច្បាប់លេខ ០២ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ១៩៨០ ។

**មាត្រា ៨** - ការធ្វើអោយបែកការសម្ងាត់ និង ការធ្វើអោយបាត់ឯកសារសម្ងាត់ ។

យោធាណា ដែលផ្សាយការសម្ងាត់ យោធាដល់អ្នកដទៃដែលជាជនគ្មានការទទួល ខុសត្រូវក្នុងរឿងសម្ងាត់នោះ ឬ យោធាណាដែលធ្វើអោយបាត់ឯកសារ សម្ងាត់ ដោយការធ្វេសប្រហែស ត្រូវផ្តន្ទាទោស ដាក់គុកពី ៦ ខែ ទៅ ៣ ឆ្នាំ ។

**មាត្រា ៩** – ការខ្វះស្មារតីទទួលខុសត្រូវ និង ការមិនយកចិត្ត ទុកដាក់ ក្នុងការងាររបស់ខ្លួន បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរ ។

យោធាណាខ្វះស្មារតី ទទួលខុសត្រូវ ឬមិនយកចិត្តទុកដាក់ នឹងការងាររបស់ ខ្លួន បណ្តាលអោយមានការខូចខាតធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់គុក ពី ៦ខែ ទៅ ៣ ឆ្នាំ ។ បើការខូចខាតនោះ មានលក្ខណៈ ធ្ងន់ធ្ងរពិសេស ជនប្រព្រឹត្តិ បទល្មើសអាចត្រូវផ្តន្ទាទោស ដាក់គុករហូតដល់ ១០ ឆ្នាំ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
Downloaded from http://www.khmerlaws.com
Downloaded from http://www.khmerlaws.org

**មាត្រា ១០** – ការគេចវេះពី បរិចារកិច្ច យោធា ។

យោធាណាក្នុងគោលបំណង គេចវេះពី បរិចារកិច្ចយោធាហើយដែលត្រូវ បានអប់រំជាច្រើនលើក នៅតែមាន រត់ចោលជួរ ឬ ធ្វើអោយខ្លួនឯងមានរបួស ឬ មាន ជំងឺបណ្តាល អោយបាត់សម្បទាក្នុងការប្រយុទ្ធ និងក្នុង ពលកម្ម ឬ ប្រើឧបាយកល ទុច្ចរិតផ្សេងៗទៀតដើម្បីគេចវេះ ពីបរិច្ចារកិច្ចយោធា ត្រូវផ្តន្ទាទោស ដាក់គុកពី ៦ខែ ទៅ៦ ឆ្នាំ។ ក្នុងករណីធ្ងន់ធ្ងរ ដូចជាការជំរុញ ជនច្រើនរូបអោយរត់ចោលជួរ ការរត់ចោលជួរដោយយកទៅជាមួយ នូវគ្រឿងអាវុធបរិក្ខាសំខាន់ៗ របស់កងទ័ព ឬ ការប្រព្រឹត្តិបទល្មើស ព្រហ្មទណ្ឌផ្សេងៗ ទៀត ជន ប្រព្រឹត្តិ បទល្មើស អាចត្រូវផ្តន្ទាទោស ដាក់គុករហូតដល់ ៩ ឆ្នាំ។

**មាត្រា ១១** – បទល្មើសផ្សេងៗទៀត

យោធាណា ប្រព្រឹត្តិបទល្មើស ព្រហ្មទណ្ឌ ទាំងឡាយ ដែលមានចែងក្នុងក្រឹត្យ -ច្បាប់ លេខ ០២ ក.ច ចុះថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ១៩៨០ ត្រូវផ្តន្ទាទោស តាមទណ្ឌកម្ម ដែលមានកំណត់ក្នុងក្រឹត្យច្បាប់ លេខ ០២ ក.ច ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៨០ នេះ ។

**មាត្រា ១២** – ក្រឹត្យ - ច្បាប់នេះ ត្រូវអនុវត្ត ទៅលើបទល្មើស ទាំងឡាយដែលបានកើតឡើង តាំងពីថ្ងៃ ទី៧ មករា ឆ្នាំ ១៩៧៩ ហើយដែលពុំទាន់បានដាក់ជុំនំជំរះ នៅឡើយ ។

**មាត្រា ១៣** – រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធមិ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តក្រឹត្យ - ច្បាប់ នេះ តាមភារកិច្ច រៀងៗខ្លួន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ១៩៨១

បានដាក់ជូនក្រុមប្រឹក្សារដ្ឋ
ចុះហត្ថលេខាដោយរដ្ឋមន្ត្រី
ក្រសួងការពារប្រទេស និង
រដ្ឋមន្ត្រីក្រសួងយុត្តិធមិ

ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា
**ហេង សំរិន**

រដ្ឋមន្ត្រីក្រសួងការពារប្រទេស
ហត្ថលេខា និងត្រា
**ចាន់ ស៊ី**

រដ្ឋមន្ត្រី ក្រសួងយុត្តិធមិ
ហត្ថលេខា និងត្រា
**អ៊ុក ប៊ុនឈឿន**

បានទទួលអនុវត្ត
ជ.ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ចាន់ ស៊ី**


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
Downloaded from http://www.khmerlaws.com
Downloaded from http://www.khmerlaws.org

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
Downloaded from http://www.khmerlaws.com
Downloaded from http://www.khmerlaws.org